**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
លេខ៧៤៨.លស.កសស.គណ.ហវ

ថ្ងៃសុក្រ ១៥ កើត ខែជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
ខេត្តព្រះសីហនុ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០២០

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី លទ្ធផលមហាសន្និបាតភាគហ៊ុនិក លើកទី៣
# របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា ៖ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០៨:០០ ព្រឹក កសស បានធ្វើមហាសន្និបាតភាគហ៊ុនិកលើកទី៣ ក្រោមអធិបតីភាព ឯកឧត្តម លូ គឹមឈន់ ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាត ។ អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៣ បានរៀបចំឡើងនៅ សណ្ឋាគារ សុខា ប៊ិច រីសត ដែលមានកូរ៉ុម ចំនួន ៩៤,៣២% ស្មើនឹង ៨០.៨៩៦.៦២០ ភាគហ៊ុន និងទទួលបាលទ្ធផលដូចខាងក្រោម ៖

- របាយការណ៍លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០១៩
- របាយការណ៍ ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣១ ធ្នូ ២០១៩ (បានធ្វើសវនកម្ម)
- ទិសដៅការងារឆ្នាំ២០២០
- វិធានការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19)
- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០១៩
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (Record date) គឺនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៣ បានបិទបញ្ចប់នៅវេលាម៉ោង ១១:០០នាទី នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

តិរៈវិថី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សង្កាត់៣ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ
Terak Vithei Samdech Akka Moha Sena Padei Techo **Hun Sen**, Sangkat 3
Preah Sihanouk City, Preah Sihanouk Province.
**ទូរស័ព្ទ** : (855)34 933 715 **ទូរសារ** : (855)34 933 693
Phone : (855)34 933 715 Fax : (855)34 933 693
Email: accounting@pas.gov.kh www.pas.gov.kh